ក្រសួងអភិវឌ្ឍន៍ជនបទ
ចូល
លេខ:........ក.អ.ជ
ថ្ងៃទី........ម៉ោង........
បញ្ជូន........

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០៧.សរ**

# សារាចរ
## ស្តីពី
## ការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូននគរបាលជាតិនិងយោធិន

ដើម្បីធានាការបើកផ្តល់បៀវត្សជូននគរបាលជាតិនិងយោធិនបានឆាប់រហ័ស ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១. ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសារនគរបាលជាតិនិងយោធិន និងការពិនិត្យនិងរៀបចំតារាងគិតគូរការគ្រោងបៀវត្សប្រចាំខែនីមួយៗ÷
- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវពិនិត្យនិងរៀបចំតារាងសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសារនគរបាលជាតិនិងយោធិន ជារៀងរាល់ខែ ព្រមទាំងត្រូវពិនិត្យនិងរៀបចំតារាងគិតគូរការគ្រោងបៀវត្សប្រចាំខែនីមួយៗ ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ ឱ្យបានត្រឹមត្រូវ។

២. ការរៀបចំអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ
- អាណត្តិបើកប្រាក់បៀវត្សប្រចាំខែ ត្រូវរៀបចំសម្រាប់តែចំណាយលើបៀវត្សតែប៉ុណ្ណោះ។

៣. ការពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងនាមជាអាណាប័កដើមខ្សែ ពិនិត្យនិងចុះហត្ថលេខាដោយផ្ទាល់លើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ ឬ អាចធ្វើប្រតិភូកម្មដល់អាជ្ញាធរក្រោមបង្គាប់ ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអាណត្តិបើកប្រាក់បៀវត្សប្រចាំខែក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិដូចខាងក្រោម÷
  - ថ្នាក់ដឹកនាំក្រសួង ឬ
  - អគ្គនាយកទទួលបន្ទុកនាយកដ្ឋានហិរញ្ញវត្ថុឬអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ ឬ
  - ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ឬ ប្រធានអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ។
- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវបោះផ្សាយអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ ហើយបញ្ជូនយ៉ាងយូរត្រឹមថ្ងៃទី១៨នៃខែនីមួយៗ មកមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ដែលទទួលបន្ទុកក្រសួងនីមួយៗ ដើម្បីពិនិត្យនិងផ្តល់ទិដ្ឋាការ និងត្រូវផ្តល់ឯកសារចម្លងមួយច្បាប់ទៅឱ្យអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផងដែរ

- មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យនិងផ្តល់ទិដ្ឋាការយ៉ាងយូរត្រឹមថ្ងៃទី២១នៃខែនីមួយៗ
- អាណត្តិបើកប្រាក់បៀវត្សប្រចាំខែដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ក និងទទួលបានទិដ្ឋាការហើយ ត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរត្រឹមថ្ងៃទី២២នៃខែនីមួយៗ។

៤. ការបើកផ្តល់បៀវត្សដល់នគរបាលជាតិនិងយោធិន÷

- អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ចែងការត្រួតពិនិត្យនិងរៀបចំបើកផ្តល់បៀវត្សដល់ក្រសួងមហាផ្ទៃនិងក្រសួងការពារជាតិ ឱ្យបានទាន់ក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ បន្ទាប់ពីទទួលបានអាណត្តិបើកប្រាក់បៀវត្សប្រចាំខែតាមកាលកំណត់ខាងលើ
- ក្នុងករណី អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនបានទទួលអាណត្តិបើកប្រាក់បៀវត្សប្រចាំខែដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ក និងទទួលបានទិដ្ឋាការហើយតាមកាលកំណត់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិនិងរតនាគាររាជធានី ខេត្ត) ត្រូវចាត់ចែងបើកបៀវត្សដល់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ដោយធ្វើការបុរេប្រទានសាច់ប្រាក់ផ្អែកតាមឯកសារចម្លងនៃអាណត្តិបើកប្រាក់បៀវត្សប្រចាំខែដែលបានផ្តល់ឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ
- ក្នុងករណី អគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនបានទទួលអាណត្តិបើកប្រាក់បៀវត្សប្រចាំខែដែលត្រូវបានចុះហត្ថលេខាដោយអាណាប័ក និងទទួលបានទិដ្ឋាការហើយតាមកាលកំណត់ ព្រមទាំងមិនបានទទួលឯកសារចម្លងនៃអាណត្តិបើកបៀវត្សប្រចាំខែដែលត្រូវផ្តល់ឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិនិងរតនាគាររាជធានី ខេត្ត) ត្រូវធ្វើការបុរេប្រទានសាច់ប្រាក់ផ្អែកតាមអាណត្តិបើកប្រាក់បៀវត្សខែមុនឱ្យបានទាន់ពេលវេលាកំណត់
- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវបានចាត់ទុកថា ផ្តល់ការឯកភាពជាស្វ័យប្រវត្តិលើការទូទាត់បើកបៀវត្សប្រចាំខែ ចំពោះករណីខកខានខាងលើ ប៉ុន្តែក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវផ្តល់លិខិតយុត្តិការនិងអាណត្តិបើកប្រាក់បៀវត្សប្រចាំខែដែលចុះហត្ថលេខារួចដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកតាមករណីពាក់ព័ន្ធនីមួយៗ ដើម្បីធ្វើការទូទាត់ជិះបញ្ជីបុរេប្រទាននោះតាមក្រោយឱ្យស្របតាមនីតិវិធីហិរញ្ញវត្ថុ។ ក្នុងករណីមានភាពលំអៀងរវាងបុរេប្រទាននិងអាណត្តិបើកប្រាក់បៀវត្សដែលមកដល់យឺត ត្រូវធ្វើការបំពេញបន្ថែម ឬ កាត់កងនៅខែបន្ទាប់

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំកំណត់បែបបទនិងនីតិវិធីហិរញ្ញវត្ថុសម្រាប់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ព្រមទាំងរៀបចំតារាងពេលវេលានៃការបើកផ្តល់បៀវត្សដោយកំណត់ថ្ងៃជាក់លាក់តាមលំដាប់លំដោយក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ
- ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវរៀបចំនីតិវិធីផ្ទៃក្នុងក្រសួង ដើម្បីធានាឱ្យប្រាកដថា នគរបាលជាតិនិងយោធិនម្នាក់ៗ ទទួលបានបៀវត្សដោយផ្ទាល់និងទៀងទាត់ស្របតាមខ្លឹមសារនៃសារាចរនេះនិងកំណត់ឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវក្នុងការរក្សាឯកសារដើមនៅសាមីអង្គភាពរបស់ខ្លួន។

៥. គណនេយ្យភាពនិងការទទួលខុសត្រូវ

- អាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនឹងបៀវត្ស និងអាណត្តិបើកប្រាក់បៀវត្សប្រចាំខែរបស់នគរបាលជាតិ និងយោធិនដូចដែលបានចង្អុលបង្ហាញខាងលើ ត្រូវចាត់ចែងបំពេញភារកិច្ចដោយផ្ទាល់ ឬ ធ្វើប្រតិភូកម្មដល់អាជ្ញាធរស្ថិតក្រោមបង្គាប់ ដើម្បីបំពេញការងារឱ្យទាន់ពេលវេលាកំណត់
- អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវអនុវត្តភារកិច្ចតាមខ្លឹមសារនៃសារាចរនេះ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្អែកតាមកម្រិតឋានានុក្រម និងចំពោះនគរបាលជាតិនិងយោធិនដែលត្រូវទទួលបៀវត្សក្នុងខែនីមួយៗ ព្រមទាំងត្រូវមានការទទួលខុសត្រូវផ្សេងទៀតជាយថាហេតុផ្អែកតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

ទទួលបានសារាចរនេះក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*
- *គ្រប់សាលារាជធានី ខេត្ត*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*